ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
លេខ : ២២ កយ.ប្រក/២៤

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តនានា

២០២៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០៦២ កណ.ប្រក/២៤

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិ នៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១ .-**

បង្កើតក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលមានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **កែវ សុម៉ារិទ្ធ** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | **សួរ ចាន់ធី** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម | **ញ្ញាន វណ្ណះ** | រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤-ឯកឧត្តម | **តាន់ហ៊ាង ដាវ័ណ្ណ** | រដ្ឋលេខាធិការ | អនុប្រធាន |



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

| | | | |
|---|---|---|---|
| ៥-ឯកឧត្តម | **យឹម សារី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៦-ឯកឧត្តម | **ទឹម ស៊ីផា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧-លោកជំទាវ | **សុខ ឆវ័ន្ត** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨-ឯកឧត្តម | **ម៉ែន ពេជ្រសាលី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ | សមាជិក |
| ៩-ឯកឧត្តម | **ឡាយ ឈាងសេង** | ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ១០-ឯកឧត្តម | **ខាត់ ឆវ័ន្ត** | ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ១១-ឯកឧត្តម | **នុប សុធនវិសុទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការ អយ្យការ និងព្រហ្មទណ្ឌ | សមាជិក |
| ១២-លោកជំទាវ | **សុន សុខាលីដា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការ អយ្យការ និងព្រហ្មទណ្ឌ | សមាជិក |
| ១៣-លោកជំទាវ | **គា ម៉ីម៉ី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការ អយ្យការ និងព្រហ្មទណ្ឌ | សមាជិក |
| ១៤-ឯកឧត្តម | **សេង ពុទ្ធី** | ប្រធាននាយកដ្ឋានកិច្ចការច្បាប់ព្រហ្មទណ្ឌ | សមាជិក |
| ១៥-លោកជំទាវ | **សុខ វិសាល** | ប្រធាននាយកដ្ឋានកិច្ចការអយ្យការ | សមាជិក |
| ១៦-លោកជំទាវ | **ម៉ែន ផល្លីភារ** | ប្រធាននាយកដ្ឋានកិច្ចការយុត្តិធម៌ព្រហ្មទណ្ឌ និងនគរបាលយុត្តិធម៌ | សមាជិក |
| ១៧-លោក | **លី សុផាណា** | ប្រធាននាយកដ្ឋានស៊ើបអង្កេត និងស្រាវជ្រាវ | សមាជិក |
| ១៨-លោក | **ហោ ឈុនឡុង** | សមាជិកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ១៩-កញ្ញា | **គន្ធា ស្រីសុជាតា** | សមាជិកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ២០-កញ្ញា | **នៅ សុនិតា** | សមាជិកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ២១-លោក | **ឆុន ករុណា** | សមាជិកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ២២-លោក | **សុទ្ធ ម៉ូលីណា** | អនុប្រធាននាយកដ្ឋានកិច្ចការ ច្បាប់ព្រហ្មទណ្ឌ | សមាជិក |
| ២៣-លោក | **ម៉េង ចាន់រតនា** | ប្រធានការិយាល័យ | លេខាធិការ |
| ២៤-លោក | **ង៉ូ ទីឡេង** | ប្រធានការិយាល័យ | លេខាធិការ |
| ២៥-លោក | **អៀម សំណាង** | ប្រធានការិយាល័យ | លេខាធិការ |
| ២៦-លោក | **ហាក់ សុខម៉េង** | ប្រធានការិយាល័យ | លេខាធិការ |
| ២៧-លោកស្រី | **ហួន ធីតា** | អនុប្រធានការិយាល័យ | លេខាធិការ។ |

**ប្រការ២ ..**

ក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ ផ្ដល់យោបល់ និងកែតម្រូវលើផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សំដៅធានាសង្គតិភាព និងអនុលោមភាពនៃការរៀបចំខ្លឹមសារផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- ដឹកនាំកិច្ចប្រជុំជាមួយក្រសួង ស្ថាប័នសាមី ដើម្បីពិនិត្យ ផ្ដល់យោបល់ និងកែតម្រូវលើផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- រៀបចំផែនការការងារដើម្បីពិនិត្យ និងផ្ដល់យោបល់លើផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដោយកំណត់លំដាប់អាទិភាពនៃការងារឱ្យបានច្បាស់លាស់
- រៀបចំរបាយការណ៍ និងកំណត់ហេតុកិច្ចប្រជុំពិនិត្យ ពិភាក្សា ផ្ដល់យោបល់ និងកែតម្រូវផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- រៀបចំសេចក្ដីព្រាងលិខិតឆ្លើយតបទៅក្រសួង ស្ថាប័នសាមី អំពីយោបល់របស់ក្រសួងយុត្តិធម៌លើផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- សិក្សាស្រាវជ្រាវ និងរៀបចំសេចក្ដីព្រាងគោលការណ៍ណែនាំស្ដីពីការរៀបចំតាក់តែងផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាប្រសិទ្ធភាព សង្គតិភាព និងឯកភាពផ្ទៃក្នុងលើការអនុវត្តការងារពិនិត្យ និងផ្ដល់យោបល់លើផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំឆមាស ប្រចាំនព្វមាស និងប្រចាំឆ្នាំ អំពីវឌ្ឍនភាពនៃការពិនិត្យ ផ្ដល់យោបល់ និងកែតម្រូវលើផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងវឌ្ឍនភាពការងារពាក់ព័ន្ធផ្សេងទៀត
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៣ ..**

អនុប្រធាន សមាជិក និងលេខាធិការនៃក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានអាចកោះប្រជុំ និង/ឬ ដឹកនាំកិច្ចប្រជុំជំនួសបាន តាមការប្រគល់សិទ្ធិពីប្រធាន។

ប្រធានក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា អាចអញ្ជើញអ្នកជំនាញ ឬមន្ត្រីជំនាញពាក់ព័ន្ធឱ្យចូលរួមប្រជុំពិគ្រោះយោបល់តាមការចាំបាច់។

**ប្រការ៤ ..**

ប្រធានក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា អាចរៀបចំបែងចែកជាអនុក្រុមការងារមួយចំនួនតាមការចាំបាច់ ដើម្បីបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

ក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិនៃសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួន តាមការចាំបាច់។

**ប្រការ៥ ._**

ក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ប្រើប្រាស់ថវិការបស់នាយកដ្ឋានកិច្ចការច្បាប់ព្រហ្មទណ្ឌនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ ដើម្បីបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

សមាសភាពនៃក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា អាចទទួលបានប្រាក់រង្វាន់លើកទឹកចិត្ត ដោយផ្អែកលើសមិទ្ធកម្មការងារ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៦ ._**

ប្រកាសលេខ ១៨១ កយ.ប្រក/២២ ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារដឹកនាំការត្រួតពិនិត្យផ្នែកទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២ រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ